ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ធំ**

រឿងក្តីលេខ៖ ២៣១ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

សញ្ញាណនៃរឿងក្តី ៖ ទាមទារប្រាក់

ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧

សាលក្រមលេខ ៖ ៧៧ "ក"

ថ្ងៃប្រកាសសាលក្រម ៖ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧

**តាងនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្តកំពង់ធំ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសសាលក្រមជាសាធារណៈ
នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧ ដែលមានសមាសភាពដូចតទៅ ៖

ចៅក្រមជំនុំជម្រះ

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម** -លោក [redacted] ប្រធានសាលាដំបូង

**ថ្ងៃទី ១៤ ខែ ៥ ឆ្នាំ២០១៨**

**ហត្ថលេខានិងត្រា**

ក្រឡាបញ្ជីសវនាការ

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

**ដើមចោទ**

-[redacted] អាយុ៤៨ឆ្នាំ មុខរបរ ធ្វើស្រែ [redacted]

-ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

**ចុងចម្លើយ**

-ឈ្មោះ [redacted] ចន្ថា ភេទស្រី អាយុ៥២ឆ្នាំ មុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃ [redacted]

-មេធាវីតំណាងដោយអាណត្តិ គ្មាន ។

**អង្គហេតុ និង ចំណុចទាមទារ**

**១.ការទាមទារ**

១-សុំទាមទារប្រាក់ដើមសរុបចំនួន ១៦,០០០.០០០ (ដប់ប្រាំមួយលាន) រៀល

Scanned with CamScanner

២-សុំទាមទារការប្រាក់ ចំនួន ២ % ក្នុងមួយខែ លើប្រាក់ដើម គិតចាប់ពីថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៧ រហូតដល់សងគ្រប់ ។

៣-សុំទាមទារខាតបង់ការចំណាយលើសេវាកម្មច្បាប់ចំនួន ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក

៤-សុំទាមទារឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដីតុលាការទាំងអស់ ។

**២.ការពន្យល់គ្រួសៗអំពីរឿងក្ដី៖**

២.១ ក្នុងរឿងក្ដីនេះ ចុងចម្លើយឈ្មោះ [redacted] ចន្ថា បានដីចំនួន០១ប្លង់ ទំហំ ១០ ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ ដែលមានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ [redacted] សំអាត ខាងលិចទល់នឹងឈ្មោះ [redacted] សារ៉ាំ ខាងជើងទល់នឹង ផ្លូវថ្នល់ និងខាងត្បូងទល់នឹងឈ្មោះ [redacted] សារ៉ាំ [redacted] មកដាក់ធានាសុំខ្ចីលុយពីដើមចោទឈ្មោះ [redacted] បុទុម ចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល ដោយគិត ការប្រាក់ចំនួន ២ % ក្នុងមួយខែ និងបានធ្វើកិច្ចសន្យាលាយលក្ខអក្សរ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ មានរដ្ឋ អំណាចឃុំដឹងលឺត្រឹមត្រូវ តែដើមចោទបានបង់ការប្រាក់ទៀងទាត់ត្រឹមខែ កុម្ភៈ ឆ្នាំ ២០១៧ ហើយក៏ឈប់បង់រហូត។

២.២ អង្គហេតុដែលគ្មានវិវាទ៖

- ដើមចោទ និង ចុងចម្លើយ បានចុះកិច្ចសន្យាខ្ចីបរិភោគជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ ដោយខ្ចីប្រាក់ដើមចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល អត្រាការប្រាក់ ២ % (ពីរភាគរយ) ក្នុងមួយខែ ។
- ក្នុងកំឡុងពេលដែលត្រូវសង តែចុងចម្លើយមិនបានសងប្រាក់ទៅដើមចោទវិញទេ ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ១៤ ខែ ៥ ឆ្នាំ២០១៨
ហត្ថលេខានិងត្រា
ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA
មេធាវី [redacted]

២.៣ ចំណុចវិវាទ

- ដើមចោទទាមទារប្រាក់ជំពាក់ ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល តែចុងចម្លើយ ថាសងខ្លះហើយ នៅជំពាក់តែប្រហែល ៤.០០០.០០០ (បួនលាន) រៀល ។
- ដើមចោទទាមទារការប្រាក់ ២ % ក្នុងមួយខែ តែចុងចម្លើយថាមិនមានលទ្ធភាពសងទៀត ទេ ។
- ដើមចោទទាមទារខាតបង់ការចំណាយលើសេវាកម្មច្បាប់ចំនួន ៨០០ (ប្រាំបីរយ) ដុល្លារ អាមេរិក តែចុងចម្លើយថាមិនមានលទ្ធភាពសងទេ ។

**៣.ការអះអាងរបស់គូភាគី**

៣.១ ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖ មេធាវីតំណាងដោយអាណត្តិឲ្យ ដើមចោទអះអាងថាខ្លួននៅតែប្ដឹងអោយតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ចន្ថា សងប្រាក់ដើម មកឲ្យកូនក្ដីខ្លួន ចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល . ការប្រាក់ ចំនួន ២ % ក្នុងមួយខែ និងការ ចំណាយលើសេវាកម្មច្បាប់ចំនួន ៨០០ (ប្រាំបីរយ) ដុល្លាអាមេរិក ដោយហេតុថាឈ្មោះ [redacted] ចន្ថា បានដីចំនួន០១ ប្លង់ ទំហំ ១០ ម៉ែត្រ គុណនឹង ៥០ ម៉ែត្រ ដែលមានព្រំប្រទល់ខាងកើតទល់នឹងឈ្មោះ [redacted] សំអាត ខាងលិចទល់ នឹងឈ្មោះ [redacted] សារ៉ាំ ខាងជើងទល់នឹង ផ្លូវថ្នល់ និងខាងត្បូងទល់នឹងឈ្មោះ [redacted] សារ៉ាំ ស្ថិតនៅភូមិកំពង់ឈើទាល ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មកដាក់ធានាសុំខ្ចីលុយពីដើមចោទឈ្មោះ [redacted] បុទុម ចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល ដោយគិត ការប្រាក់ចំនួន ២ % ក្នុងមួយខែ និងបានធ្វើកិច្ចសន្យាលាយ លក្ខអក្សរ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ មានរដ្ឋ អំណាចឃុំដឹងលឺត្រឹមត្រូវ តែដើមចោទបានបង់ការប្រាក់ទៀង ទាត់ត្រឹមខែ កុម្ភៈ ឆ្នាំ ២០១៧ ហើយក៏ឈប់បង់រហូតដល់សព្វថ្ងៃ។ ដូច្នេះខ្លួនសំណូមពរដល់តុលាការចេញសាលក្រម បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ចន្ថា សងប្រាក់ដើមមកឲ្យកូនក្ដីខ្លួនចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ការប្រាក់ ២% ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ រហូតដល់សងគ្រប់ចំនួន . ទាមទារការខាត បង់ចំណាយសេវាកម្មច្បាប់ចំនួន ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក និងសុំឲ្យចុងចម្លើយជាអ្នកបង់ប្រាក់ប្រដាប់ក្ដី។

Scanned with CamScanner

៣.៦ ការអះអាងរបស់ចុងចម្លើយ ៖ ចុងចម្លើយបានអះអាងថាខ្លួនទទួលស្គាល់ថាខ្លួនបានចងការលុយរបស់ឈ្មោះ [redacted] ប៉ុន្មែប្រាកដមែន តែខ្លួនសងបណ្ដើរៗរហូត មកដល់ពេលជាងដប់ឆ្នាំហើយ ខ្លួនខ្ចីគាត់ដំបូង ១១.០០០.០០០ (ដប់មួយលាន) រៀល ក្រោយមក ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល សរុបចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល ខ្លួនអោយការប្រាក់ ១.៨៥០.០០០ (មួយលានប៉ែតសិបប្រាំម៉ឺន) រៀល ក្នុងមួយខែ ។ នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៧ ខ្លួនឲ្យគាត់ចំនួន ៩០០.០០០ (កៅសិបម៉ឺន) រៀល នៅខ្វះ ចំនួន ៩០០.០០០ (កៅសិបម៉ឺន) រៀល ទៀត ។ ចំពោះការបងលុយឲ្យឈ្មោះ [redacted] ប៉ុន្មែ គឺមិនបានធ្វើឯកសារអ្វីបញ្ជាក់ទេ ។ ខ្លួនទទួលស្គាល់ថាមិនបានសងប្រាក់អោយគាត់ចាប់ពីថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៧ រហូតដល់សព្វថ្ងៃ តែខ្លួនមិនមានលទ្ធភាពសងការប្រាក់អោយគាត់ទៀតទេ ហើយខ្លួនសុំសងលុយគាត់ជាដំណាក់ៗ ចំពោះសំណងការខូចខាត ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិកនោះ ខ្លួនគ្មានលទ្ធភាពសងទេ ។

៣.៨ ការសន្និដ្ឋានរបស់មេធាវី ៖ មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្ដីសន្និដ្ឋានថា សុំឲ្យតុលាការចេញសាលក្រមឲ្យចុងចម្លើយឈ្មោះ [redacted] ចន្ថា សងប្រាក់ដើមមកឲ្យកូនក្ដីខ្លួន ចំនួន ១៦,០០០.០០០ (ដប់ប្រាំមួយលាន) រៀល . ការប្រាក់ ចំនួន ២ % ក្នុងមួយខែ ចាប់ពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ រហូតសងគ្រប់ចំនួន . ការខាតបង់ចំនួន ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក និងឲ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដី ដោយផ្អែកលើកិច្ចសន្យាចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ និងការដាក់ធានាខ្ចីប្រាក់ ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និង ការពិនិត្យកស្ដុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖

១.ដើមចោទ និង ចុងចម្លើយ បានចុះកិច្ចសន្យាខ្ចីបរិភោគជាលាយលក្ខណ៍អក្សរ នៅថ្ងៃនៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦ ដោយខ្ចីប្រាក់ដើមចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល អត្រាការប្រាក់ ២ % (ពីរ) ក្នុងមួយខែ ។ តុលាការយល់ឃើញថា កិច្ចសន្យានេះ ធ្វើឡើងដោយមានការព្រមព្រៀង និងមានផ្ដិតស្នាមមេដៃរបស់ភាគីទាំងពីរ គឺមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៥៧៩ និងមាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណី ដូចនេះ តុលាការគប្បីទទួលស្គាល់ ។

២.ចុងចម្លើយទទួលស្គាល់ថា ខ្លួនបានទទួលប្រាក់ដើមពីដើមចោទសរុប ចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល ត្រឹមត្រូវតាមកិច្ចសន្យា តែខ្លួនបានបង់ប្រាក់អោយគាត់បានខ្លះហើយ ទាំងដើម និង ការប្រាក់គឺក្នុងមួយខែ ១.៨៥០.០០០ (មួយលានប៉ែតសិបប្រាំម៉ឺន) រៀល រហូតមកដល់ពេលនេះខ្លួននៅជំពាក់ប្រាក់ដើមប្រហែល ៤.០០០.០០០ (បួនលាន) រៀល ប៉ុណ្ណោះ ហើយខ្លួនក៏ឈប់បង់ ចាប់ពីថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៧ មកមែន។ ប៉ុន្តែពេលបង់ប្រាក់អោយគាត់ មិនបានធ្វើឯកសារអ្វីដើម្បីបញ្ជាក់ទេ ការអះអាងនេះមិនអាចឲ្យតុលាការជឿបានឡើយ ព្រោះពុំមានឯកសារណាមកបញ្ជាក់បានឡើយ ។

៣.តាមសំអាងហេតុខាងលើនេះបានបង្ហាញពីអត្ថិភាពនៃសិទ្ធិលើបំណុលរបស់ដើមចោទមានលើចុងចម្លើយ លើទំហំប្រាក់ដើមចោទចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល ។ ដូចនេះ ការទាមទារប្រាក់ដើមរបស់ដើមចោទនេះ តុលាការគប្បីទទួលស្គាល់ ។

៤.កិច្ចសន្យាខ្ចីបរិភោគរវាងដើមចោទ និង ចុងចម្លើយបានចែងអំពីអត្រាការប្រាក់ ២ % ភាគរយ ក្នុងមួយខែ គឺស្របតាមប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត ដូចនេះតុលាការគប្បីទទួលស្គាល់ ។

៥.ដោយការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយជាកូនបំណុល ដើមចោទអាចទាមទារសំណងនៃការខូចខាតបានតាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី។ ដើមចោទទាមទាប្រាក់សំណងការខូចខាតចំនួន ៨០០ (ប្រាំបីរយ) ដុល្លារអាមេរិក តុលាការគប្បីលលើកយកមកពិចារណា ។

៦.[illegible] ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី។

បានថតចម្លងត្រឹមត្រូវ[illegible]

ថ្ងៃទី ១៤ ខែ [illegible]

ហត្ថលេខា [illegible]

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

## សេចក្ដីសម្រេចបញ្ចប់

មេធាវី [redacted]

Scanned with CamScanner

១.ឲ្យចុងចម្លើយឈ្មោះ [redacted]ចន្ថា បង់សងប្រាក់ជំពាក់ប្រាក់ដើមចោទចំនួន ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល ទៅឲ្យឈ្មោះ [redacted] ប៊ុទុម នៅពេលសាលក្រមចូលជាស្ថាពរ ។

២.ឲ្យចុងចម្លើយឈ្មោះ [redacted]ចន្ថា បង់សងការប្រាក់តាមអត្រា ២ % (ពីរភាគរយ) ក្នុងមួយខែ លើប្រាក់ដើម ១៦,០០០,០០០ (ដប់ប្រាំមួយលាន) រៀល ទៅឲ្យឈ្មោះ [redacted]ប៊ុទុម គិតចាប់ពីថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៧ រហូតដល់សងគ្រប់ នៅពេលសាលក្រមចូលជាស្ថាពរ។

៣.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted]ចន្ថា បង់សងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងចំណាយផ្សេងៗ ចំនួន ២.០០០.០០០ (ពីរលាន) រៀល ទៅឈ្មោះ [redacted]ប៊ុទុម នៅពេលសាលក្រមចូលជាស្ថាពរ ។

៤.រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់រួចហើយ។ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបានទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

កំពង់ធំ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

កំពង់ធំ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៧

**ក្រឡាបញ្ជី**

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**ថ្ងៃទី ១៤ ខែ ៦ ឆ្នាំ២០១៧**

**ហត្ថលេខា និង ត្រា**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

[redacted]